ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ.០៩៥៨/២២.....រ.ប.ក

# របាយការណ៍ខែមីនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែមេសា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួន ០២ គឺ
  - ✓ ជាមួយអង្គការ **Erikshjalpen** ស្តីពីសកម្មភាពបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២)។
  - ✓ ជាមួយអង្គការ វីនរ៉ក់អន្តរជាតិ ដើម្បីរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១.១. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ **Aple Cambodia** បន្តផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ ស្តីពី «យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយទំនួលខុសត្រូវ» ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដល់សាលាប៉ៃលជីអន្តរជាតិ មានលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចូលរួមសរុបប្រមាណ ២៥០នាក់។

- **ខេត្តកំពត៖** បានផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំគ.ក.ស.ក និងកិច្ចប្រជុំ គ.ក.ន.ក សរុប**២៧**លើក អ្នកចូលរួមសរុប **២៨៩**នាក់ ស្រី**២៧៩**នាក់។
- **ខេត្តកណ្តាល៖** គ.ខ.ប.ជ បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងកិច្ចប្រជុំរៀបចំពិធីអបអរសាទរខួបលើកទី១១១ ទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០២២ ក្រោមប្រធានបទ សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត មានអ្នកចូលរួមសរុប **៥៤**នាក់។
- **ខេត្តសៀមរាប៖** រដ្ឋបាលស្រុកពួក បានរៀបចំយុទ្ធនាការផ្សព្វផ្សាយការប្រើប្រាស់សេវាការងារតាមប្រព័ន្ធអ៊ីនធឺណិត និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៃការធ្វើចំណាកស្រុកដោយស្របច្បាប់ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៦០នាក់ ស្រី**៣៤**នាក់។
- **ខេត្តព្រៃវែង៖** បានផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងល្បិចបោកប្រាសរបស់ជនឆ្លៀតឱកាសមួយចំនួន ក្នុងពិធីសម្ពោធឆ្លងសាលាកត្ត និងសមិទ្ធផលនានានៅវត្តជ្រៃឧត្តម ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត ប្រធានគណៈបញ្ជាការ ឯកភាពខេត្ត និងជាប្រធាន គ.ខ.ប.ជ។
- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈការចុះពិនិត្យថ្នាក់មត្តេយ្យសិក្សាសហគមន៍ ការចុះចងក្រងក្រុមសមាជិកមាតាបិតាថ្មី របស់គម្រោងហ្វ្រីដ ការចុះទស្សនកិច្ចសិក្សា ការបើកវគ្គបំប៉នទឹកស្អាត និងអនាម័យ ការដាំបន្លែដល់សាលារៀន ការពិនិត្យតាមដានលើការងារគ្រប់គ្រងដឹកនាំ និងការរៀនបង្រៀនក្នុងឆ្នាំសិក្សា ២០២១-២០២២ និងការពិនិត្យតាមដាន រៀបចំរចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពមេដឹកនាំក្រុមប្រឹក្សាយុវជន កុមារ ចំនួន ០៦លើក។
- **ខេត្តកំពង់ចាម៖**

  - **រដ្ឋបាលក្រុង ស្រុកទាំង១០** ៖បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំគ.ស.ន.ក និងគ.ក.ន.កពាក់ព័ន្ធទៅនឹងការចាប់រំលោភសេពសន្ថវៈទៅលើស្ត្រីនិងកុមារ និងអំពីបញ្ហាចំណាកស្រុកទៅការងារធ្វើចៀសវាងការឆបោកតាមរយៈមេខ្យល់ ។

  - **មន្ទីរអប់រំយុវជន និងកីឡាខេត្ត៖** បានផ្សព្វផ្សាយដល់សហគមន៍ស្តីអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន និងការប្រជុំក្រុមឳពុកម្តាយកុមារតូចអាយុ០ដល់៣ឆ្នាំតាមភូមិគោលដៅក្នុងឃុំ និងក្រុង-ស្រុក។ និងបានផ្សព្វផ្សាយដល់សហគមន៍ស្តីអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ដល់សិស្សដែលរៀនថ្នាក់អក្ខរកម្មវិជ្ជាជីវៈ ថ្នាក់សមមូលបឋមសិក្សា និងថ្នាក់មជ្ឈមណ្ឌលសិក្សា សហគមន៍ តាមភូមិ ឃុំ និងក្រុង-ស្រុក ដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ។

### ខ.១.២. ការអប់រំដោយផ្ទាល់

នៅក្នុងខែមីនា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៩.៧៤៤**លើក មានអ្នកចូលរួមសរុបចំនួន **៣៧៩.៣៦៣**នាក់ (ធៀបនឹងខែកុម្ភៈមានចំនួន **៤២៦.១៨៤**នាក់ គឺមានការថយចុះចំនួន **៤៦.៨២១**នាក់ ស្មើនឹង**១១**%) ក្នុងនោះស្ត្រីចំនួន **២១៥.៦១៧**នាក់នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៩ | ៣៩៥ | ២៣៥ | ៥៤ | ២.២៤៩ | ១.១៩៥ |
| | សរុប ក្រសួង ស្ថាប័ន | ៩ លើក | ៣៩៥ នាក់ | ២៣៥ នាក់ | ៥៤ លើក | ២.២៤៩ នាក់ | ១.១៩៥ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៨៤០ | ៤០.៣២៥ | ២៣.០១៦ | ១.១០៤ | ៥៥.០៥៦ | ២៦.៧២៣ |
| ៣ | ខេត្តបាត់ដំបង | ៧៦៧ | ២៦.៨១៦ | ១៤.២២៩ | ៥៤៥ | ១៥.១១៣ | ៨.៣៣២ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៣៥ | ៣៦.១៩៧ | ២១.៤៧៥ | ១៣១ | ៤.៨១៥ | ២.៥១៣ |
| ៥ | ខេត្តសៀមរាប | ៩៣ | ១.៩២១ | ១.៣៥២ | ១២៥ | ៦.១៦៨ | ២.៧០៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៩៧៣ | ១៧.៨១៤ | ៩.៦២៧ | ៥៧៨ | ៩.៩០៦ | ៤.៩៥៥ |
| ៧ | ខេត្តកំពង់ចាម | ១.៩២៤ | ១០៩.២៩៧ | ៥៦.៩៧៦ | ១.០៩០ | ៣២.៧១៨ | ១៧.៤៤០ |
| ៨ | ខេត្តព្រះសីហនុ | ៧ | ៣៦៤ | ២០៥ | | | |
| ៩ | ខេត្តព្រះវិហារ | ២៦ | ២.៥៨៦ | ១.៧៤៨ | ៦ | ២៦៤ | ១៦២ |
| ១០ | ខេត្តស្វាយរៀង | | | | ២៧៨ | ៨.២៤៣ | ៤.៤១២ |
| ១១ | ខេត្តប៉ៃលិន | ១០១ | ១.៩៣២ | ៣៤៤ | ៣៥ | ១.១១០ | ៣២៨ |
| ១២ | ខេត្តកោះកុង | ៣៥ | ៦៥៧ | ៣១៧ | | | |
| ១៣ | ខេត្តកំពត | ៣០ | ៤៣៨ | ២៧២ | ១៥ | ៥២៥ | ៣៦៨ |
| ១៤ | ខេត្តកំពង់ធំ | ៨៧ | ៦.០៨១ | ៤.៣២៩ | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ២១ | ៥៥៤ | ៣៥៦ | | | |
| ១៧ | ខេត្តកែប | ៨ | ១.៨៨៤ | ៧៤២ | ១៤ | ៥៤១ | ៣៧៦ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | ៣១៦ | ១៨.០៧៩ | ៨.៨២៦ |
| ២២ | ខេត្តត្បូងឃ្មុំ | ២ | ២.៥៦៦ | ១.៣២៤ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៤ | ៣២០ | ២២៦ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | ៨២ | ១.២៤៥ | ៥០៧ |
| | សរុប រាជធានី-ខេត្ត | ៥.៣៦៣ លើក | ២២២.៩៣៦ នាក់ | ១៣៦.៥៣៨ នាក់ | ៤.៣១៨ លើក | ១៥៣.៧៨៣ នាក់ | ៧៧.៦៤៩ នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៩.៧៤៤ លើក | | ចំនួនមនុស្សសរុប ៣៧៩.៣៦៣ នាក់ | | ចំនួនស្ត្រី ២១៥.៦១៧ នាក់ | |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៥០លើក ក្នុងមួយថ្ងៃ ០៥លើក។

- **ខេត្តសៀមរាបៈ** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន ១២០លើក (ផ្សាយផ្ទាល់៤៩លើក និងចាក់ផ្សាយឡើងវិញ៧១លើក)។
- **ខេត្តត្បូងឃ្មុំៈ** បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ស្តីពី ភូមិឃុំមានសុវត្ថិភាព គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ និងការអប់រំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០១លើក។

**ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ខេត្តកំពង់ចាមៈ**
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនចំនួន ០២លើក ស្តីពីការពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយ និងទប់ស្កាត់ភាពមិនប្រក្រតី ក្នុងថ្ងៃទិវាបុណ្យនៃក្តីស្រឡាញ់។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនចំនួន ០១លើក ស្តីពីការការពារសិទ្ធិរបស់ពលករដែលមានជំនាញទាបនៅប្រទេសថៃ។

**ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- **ខេត្តបន្ទាយមានជ័យៈ** អង្គការសាម៉ារីតាន់ភឺស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ៣.៤៦៨នាក់(ស្រី១.៣៩១នាក់) អនីតិជន១៥៥នាក់។
- **ខេត្តបាត់ដំបងៈ** អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន ៣៦៥នាក់ ស្រី២០៨នាក់ កុមារ ២៧នាក់។

**ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

**ខ.៣.១. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៤៣.៨៤០នាក់(ស្រី៦៥.៥៨៨នាក់) អនីតិជន១.៥០៣នាក់(ស្រី៦១០នាក់)ៈ
  - ចេញទៅដោយស្របច្បាប់ចំនួន ៩១.៧៧១នាក់(ស្រី៤៣.៥៩១នាក់) អនីតិជន២៩៣នាក់(ស្រី១២៩នាក់) និងមិនស្របច្បាប់ចំនួន ៥១.៦៧០នាក់(ស្រី២១.៨៥៦នាក់) អនីតិជន១.២០៣នាក់(ស្រី៤៧៦នាក់)។
  - ដាច់ការទាក់ទងចំនួនន ៣៩៩នាក់(ស្រី១៤១នាក់) អនីតិជន០៧នាក់(ស្រី០៥នាក់)។
  - កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ និងបានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត ចំនួន០២លើក មនុស្សចំនួន ០៥នាក់(ស្រី០២នាក់) អនីតិជន ០២នាក់។

**ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ និងខេត្តកោះកុង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៧៧គោលដៅ មនុស្សចំនួន ៣០១នាក់(ស្រី២២៥នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ រតនគិរី កំពត បន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ០៩លើក។

ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ចំនួន ១៣១នាក់ និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយចំនួន ៧៦នាក់។ ព្រមទាំងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមទូរស័ព្ទចំនួន ១២នាក់(ស្រី០៤នាក់) មានសេចក្តីសុខធម្មតា។

**ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុបនិងក្រុមម៉ូតូកង់បី នាក់ផ្ទះ សំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន ១.១៣៣នាក់។
- **ខេត្តរតនគិរី៖** មន្ទីរអប់រំ យុវជន និងកីឡា បានចុះពង្រឹងការងារក្រុមប្រឹក្សាកុមារកម្ពុជា និងបានធ្វើការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញមនុស្ស ការរំលោភបំពាននានាលើកុមារ ការប្រើប្រាស់គ្រឿងញៀន ជូនដល់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រធានប្រតិបត្តិ ប្រធានសាខា ក្នុងបរិបទកូវីដ-១៩ នៅសាលាបឋមសិក្សាកាឡែង ស្រុកលំផាត់ និងក្រុងបានលុង មានអ្នកចូលរួមសរុប ៥៥នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១០ករណី/១៤ករណី (ធៀបនឹងខែកុម្ភៈថយចុះ០៤ករណី) ស្មើនឹង២៨,៥៧% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១២នាក់ (ស្រី០២នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ៣៣នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុពី១៨ឆ្នាំឡើង ២២នាក់ (ប្រគល់ឱ្យគ្រួសារ៣៣នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៣ករណី/០២ករណី (កើន ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៥នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២៦នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ០៤នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ២១នាក់ (ប្រគល់ឱ្យគ្រួសារ ២៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៣ | ២៦ | ០៥ |
| *សរុប* | *០៣ ករណី* | *២៦ នាក់* | *០៥ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ០៧ករណី/១២ករណី (ថយ ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៧នាក់(ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ០៧នាក់ អាយុក្រោម១៥ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឱ្យគ្រួសារ ០៧នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ០២ |
| *សរុប* | *០៧ ករណី* | *០៧ នាក់* | *០៧ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ** បានទទួលចំនួន ១៦នាក់ (ស្ត្រី១៣នាក់) កុមារ ០១នាក់ មកពីប្រទេសចិន ១០នាក់ ម៉ាឡេស៊ី ០៥នាក់ និងប្រទេសវៀតណាម ០១នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ១០នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០១នាក់ និង ងាយរងគ្រោះ ០៥នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសម្ភាសន៍ជនរងគ្រោះ បញ្ជូនមកពីក្រៅប្រទេស ចំនួន១៤នាក់(ស្រី១២នាក់) មកពីប្រទេសចិន ១១នាក់ និងប្រទេសម៉ាឡេស៊ី ០៣នាក់ (ស្រី០១នាក់)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈទៅចិន ០៤នាក់ រងគ្រោះដោយកេងប្រវ័ញ្ចប្រាក់ឈ្នួលនៅម៉ាឡេស៊ី ០១នាក់ និងរងគ្រោះដោយស្នាក់នៅខុសច្បាប់នៅចិន និងម៉ាឡេស៊ី ០៩នាក់។
  - **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសន៍ជនទេសន្តប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន ១១០លើក មនុស្សចំនួន ១៣.៧៥៨នាក់ (ស្ត្រី ៥.៥៥០នាក់) អនីតិជន ៨៩៤នាក់។
  - **ខេត្តឧត្តរមានជ័យ៖** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៤ លើក មនុស្សចំនួន ០៥នាក់។
  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ២៩លើក មនុស្សចំនួន ៥៥២នាក់ ស្រី១៧២នាក់ អនីតិជន៩០នាក់។

### ឃ.២. ការផ្ដល់សេវា និងការស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្ដារនីតិសម្បទា សរុបចំនួន ៨០៣នាក់(ស្ត្រី៣៩៩នាក់) កុមារា៧០នាក់ កុមារី៣២២នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធនូ:/បង្ខំ ៣៧នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ៣១នាក់ ជួញដូរផ្លូវភេទ ៣៥៨នាក់ រំលោភបំពានផ្លូវភេទ ១១៩នាក់ សញ្ចារកម្ម ១៨នាក់ និងងាយរងគ្រោះ ២៤០នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្ដុះបណ្ដាល និងសិក្ខាសាលា

#### ក.១. ការងារបណ្ដុះបណ្ដាល

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយ ASEAN-ACT បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដើម្បីផ្ដល់សេវាសមស្រប ០១លើក និងសហការជាមួយអង្គការ UNICEF បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន នៅខេត្តកោះកុង ០១លើក។
- **ខេត្តសៀមរាប៖**
  - លេខាធិការដ្ឋាន សហការជាមួយ គ.ជ.ប.ជ និងអង្គការ IOM រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០១វគ្គ ដែលមានអ្នកចូលរួម ២០នាក់ ស្រី០៩នាក់។
  - មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បណ្ដុះបណ្ដាលស្ដីពី បទប្បញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារប្រកបដោយសុវត្ថិភាព ការជ្រើសរើសប្រកបដោយក្រមសីលធម៌ និងសេវាកម្មដែលឆ្លើយតបនឹងយេនឌ័រ បានចំនួន ០៤លើក នៅក្នុងស្រុកពួក អង្គរជុំ ក្រឡាញ់ និងស្រុកស្រីស្នំ មានអ្នកចូលរួមសរុប១០៣នាក់ ស្រី៤០នាក់។
- **ខេត្តព្រៃវែង** លេខាធិការដ្ឋានគ.ខ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW) បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការមិនបង្ករហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករ នៅស្រុកកំពង់ត្របែក ០១លើក អ្នកចូលរួមចំនួន ៣០នាក់ ស្រី១២នាក់។
- **ខេត្តស្វាយរៀង** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្ដុះបណ្ដាល ដោយបានបញ្ជ្រាបការយល់ដឹង អំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្ដីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្ដីពីការងារ សុខភាព និង សុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន ០៥វគ្គ អ្នកចូលរួមចំនួន ៩៦នាក់ ស្រី៤៦នាក់។
- **ខេត្តព្រះសីហនុ៖**ក្រុមការងារអន្តរជំនាញទទួលបានវគ្គបណ្ដុះបណ្ដាល ០១វគ្គ ស្ដីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនិតិវិធីស៊ើបអង្កេត ករណីជួញដូរមនុស្សអំឡុងពេលកូវីដ-១៩ ដែលមានសិក្ខាកាមចូលរួម០៥នាក់ ស្រី០១នាក់។
- **ខេត្តព្រះវិហារ៖** មន្ទីរកិច្ចការនារី សហការជាមួយអង្គការ UNFPA បើកវគ្គបណ្ដុះបណ្ដាលស្ដីពី បច្ចេកទេសផ្លូវច្បាប់ពាក់ព័ន្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស យេនឌ័រ អំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើកុមារ ០១លើក មានអ្នកចូលរួម ៣៨នាក់ ស្រី១៧នាក់។

### ក.២. សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  - សហការជាមួយ ASEAN-ACT បើកសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី កិច្ចការពារសិទ្ធិជនរងគ្រោះ និងគោលការណ៍ណែនាំ ស្ដីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្ដល់សេវាសមស្រប នៅខេត្តបាត់ដំបង មានសិក្ខាកាមចូលរួម ៣៩នាក់(ស្រី១៣នាក់ )។
  - សហការជាមួយអង្គការតេនៈអ៊ីនធើណេសិនណល បើកសិក្ខាសាលាកែសម្រួលចុងក្រោយលើនីតិវិធីស្ដីពី ដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះនិងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តព្រះសីហនុ មានសិក្ខាកាមចូលរួម ៤៦នាក់( ស្រី១៣នាក់ )។
- **បាត់ដំបង៖** សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការ ASEAN-ACT រៀបចំសិក្ខាសាលាស្ដីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក នៅស្រុកសំពៅលូន មានសិក្ខាកាម ៧៤នាក់ ស្រី៤២នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** និងអង្គការ **Cambodia Acts** បើកកិច្ចប្រជុំពិភាក្សា ស្ដីពី «គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស (ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង» មានអ្នកចូលរួមសរុប ៣៤នាក់(ស្រី០៩នាក់ )។ ក្រុមការងារកិច្ចប្រជុំបានធ្វើទស្សនកិច្ចនៅវិទ្យាល័យហ៊ុនសែនចាំយាម និងវិទ្យាល័យហ៊ុនសែនប៉ាក់ខ្លង ដើម្បីស្វែងយល់ពីស្ថានការណ៍ចំណាប់អារម្មណ៍ ប្រសិទ្ធភាព បញ្ហា និងសំណូមពរ។
- **ខេត្តសៀមរាប៖** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២១ និងទិសដៅឆ្នាំ២០២២ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានចិន្ត្រៃយ៍ គ.ជ.ប.ជ និងឯកឧត្តម **អ៊ាន យុន** ប្រធានក្រុមប្រឹក្សាខេត្ត មានអ្នកចូលរួមសរុប ២០០នាក់ ស្រី៦២នាក់។

### ខ.២. ជំនួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានជួបពិភាក្សាការងារ ជាមួយតំណាងអង្គការ JICA ប្រចាំនៅកម្ពុជា ០១លើក អង្គការវីនរ៉ក់ ០១លើក និងអង្គការវីតាសស្វីស ០១លើក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- **ខេត្តស្វាយរៀង៖** លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរង និងជាអនុប្រធានចិន្ត្រៃយ៍គ.ខ.ប.ជ បាន៖
  - ជួបប្រជុំពិភាក្សាការងារ ជាមួយក្រុមការងារស្ថានទូតសហរដ្ឋអាមេរិក លោក **ចូណាថាន អាដាម** ប្រធានផ្នែកនយោបាយ និងលោក **ស៊ុយ ហ៊ាមខេមរា** អ្នកជំនាញនយោបាយ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពលកម្មកុមារ។
  - ប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ ដល់កុមារនិងស្ត្រី ពាក់ព័ន្ធការអនុវត្តគម្រោង "ការពង្រឹងសិទ្ធិទទួលបានការអប់រំ និងការងារ តាមរយៈការចូលរួមរបស់សហគមន៍ ក្នុងគោលបំណងដើម្បីចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្ដល់សេវាគាំទ្រសម្រាប់ពលករ។
- **ខេត្តសៀមរៀប** លេខាធិការដ្ឋាន គ.ខ.ប.ជ បានផ្ដល់បទសម្ភាសន៍នៃការស្រាវជ្រាវស្ដីពី ការជួញដូរមនុស្សប្រទេសនៅក្នុងតំបន់មេគង្គប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម(TIP) របស់គម្រោង JICA និងក្រុមការងារស្រុកពួក បានទទួលជួបជាមួយអ្នកវាយតម្លៃគម្រោងស្ដីពី ការលើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World។
- **ខេត្តបន្ទាយមានជ័យ៖** លោក **ណាង វុទ្ធី** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការ JICA ស្ដីពីគម្រោងពង្រឹងបណ្ដាញក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមតំបន់មេគង្គ( ២០២១-២០២៤ )។

### គ. ការខារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៦៣លើក មានអ្នកចូលរួមសរុប ១.៣៤០នាក់ (ស្រី ៣៥៧នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២៥លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ៣៨លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមេសា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍ៈ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៣លើក) មនុស្សចំនួន ១.៣៤០នាក់ (ស្រី ៣៥៧នាក់)

| ស្ថាប័ន<br>សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ<br>- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្ដីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទនៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្ដាញភ្នាក់ងារគាំពារលើវិស័យការងារ Labour Protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ASEAN-Australia លើវិស័យប្រឆាំងការជួញដូរមនុស្ស មានអ្នកចូលរួមប្រមាណ ៥០០នាក់។<br>- ជាគណៈអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ និងជាប្រធានក្រុមការងារចុះតាមដានត្រួតពិនិត្យគោលនយោបាយរាជរដ្ឋាភិបាល។<br>- ជាអធិបតី ដឹកនាំកិច្ចប្រជុំបន្តដើម្បីពិនិត្យនិង កែសម្រួលខ្លឹមសារ និងប្រមូលធាតុចូលលើឯកសារ SOP សម្រាបកិច្ចប្រជុំទ្វេភាគី រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(កម្ពុជា) និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស(ថៃ) ស្ដីពី «ស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់» ០៣លើក មានអ្នកចូលរួម ៣១នាក់ ស្រី១១នាក់។<br>- ជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ជាមួយឯកឧត្តម **ហូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលោក **ម៉ាក ថៃយល័រ** ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់អង្គការវីនរ៉ក់អន្តរជាតិ ស្ដីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ជាអធិបតីភាពបើកអង្គសិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គ្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព រវាងគ.ជ.ប.ជ និងអង្គការឃែរអន្តរជាតិ (CARE International) ដែលមានខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ជាខេត្តគោលដៅនៃគម្រោង មានអ្នកចូលរួមសរុប ៧៤នាក់ ។<br>- ជាអធិបតីភាពបើក និងបិទវគ្គបណ្ដុះបណ្ដាល ស្ដីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាននៅខេត្តកោះកុង សហការជាមួយអាស៊ានអាក់(Asean-Act)។<br>- ជាអធិបតីភាពកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប។ |

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖

- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទនៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្តាញភ្នាក់ងារគាំពារលើវិស័យការងារ Labour Protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ASEAN-Australia លើវិស័យប្រឆាំងការជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។
- ចូលរួមពិនិត្យ និងកែសម្រួលខ្លឹមសារ និងប្រមូលធាតុចូលលើឯកសារ SOP សម្រាប់កិច្ចប្រជុំទ្វេភាគី រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សនៃរាជរដ្ឋាភិបាលថៃ ស្តីពី «ស្តង់ដារនៃនីតិវិធី ប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់»។
- ចូលរួមកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដែលមានលោក **ម៉ាក ថៃយល័រ** ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គ្រោង ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការឃែរអន្តរជាតិប្រចាំប្រទេសកម្ពុជា (CARE International) ដែលមានខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ជាខេត្តគោលដៅនៃគម្រោង។
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស (ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង "គាំទ្រដោយអង្គការ Cambodia Acts និងអង្គការ Plan International។
- ចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅខេត្តកោះកុង ដោយមានកិច្ចសហការជាមួយអង្គការ Asean-Act។
- ចូលរួមជាអធិបតីភាពកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២៩ច្បាប់ លិខិតចូល ១១ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៣ច្បាប់ លិខិតចូល ២៣ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមីនា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។

- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន១០៧ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៣០សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅខេត្តកោះកុង សហការជាមួយអាស៊ានអាក់(ASEAN-ACT)។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង គ.ជ.ប.ជ
  - ចូលរួមកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំដោយអង្គការវីនរ៉ក់អន្តរជាតិប្រចាំនៅកម្ពុជា តាមរយៈមូលនិធិរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) នៅសណ្ឋាគារសាន់វ៉េ ភ្នំពេញ។
  - ចូលរួមកិច្ចប្រជុំ ក្រុមការងារបច្ចេកទេស អន្តរក្រសួង OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ នៃការសិក្សាស្រាវជ្រាវ ស្តីពីការបញ្ឈប់គ្រោះថ្នាក់ Disrupting Ham Study ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(DH-OCSE) ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសណ្ឋាគារសាន់វ៉េ ភ្នំពេញ។
  - បានចូលរួមធ្វើគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលាខេត្តកោះកុង។
- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យពិភាក្សា និងប្រមូលធាតុចូលបញ្ចប់ លើនីតិវិធីការអនុវត្តគោលការណ៍ណែនាំ នៃដំណើរការមាតុភូមិនិវត្តន៍តាមផ្លូវអាកាស ក្រោមអធិបតីភាព ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅមន្ទីរសង្គមកិច្ចខេត្តព្រះសីហនុ មានសិក្ខាកាមចូលរួម ៤៦នាក់ ស្រី១១នាក់។
- និងបានចូលរួមបានចូលរួមធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណការប៉ះទង្គិចផ្លូវចិត្តទៅលើអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពបើក លោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូមរួមប្រជុំពិនិត្យ និងកែសម្រួលខ្លឹមសាររបាយការណ៍ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបញ្ចប់ ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ គ.ជ.ប.ជ។
  - បានចូលរួមប្រជុំជាមួយក្រុមការងារ SOMTC ក្រសួងមហាផ្ទៃ ស្ដីពីកិច្ចសហការ រវាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ជាមួយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា(ASEAN-ACT) ជំនួសលោកជំទាវឧត្តមសេនីយ៍ទោ រ៉ែន **សិរីលក្ខិណា** ជាជនបង្គោល និងជាប្រធានក្រុមការងារ SOMTC របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។
  - បានចូលរួមធ្វើជាគ្រូបង្គោល វគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន (Training on Child Protection and Identification of Human Trafficking and Abuse) នៅខេត្តកោះកុង ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង គ.ជ.ប.ជ
    - ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្ដីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទ នៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្ដាញភ្នាក់ងារគាំពារលើវិស័យការងារ Labour protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT)។
    - ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី១១ រវាងកម្ពុជា និងសហភាពអឺរ៉ុប(EU) ដែលបានរៀបចំឡើងនៅរាជធានីភ្នំពេញ ក្នុងទម្រង់ដោយផ្ទាល់ផង និងតាមរយៈវីដេអូពីចម្ងាយផង ដឹកនាំដោយឯកឧត្តម **លុយ ដាវីត** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រី PAOLA PAMPALONI អនុប្រធានគ្រប់គ្រងប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមន្ទីរកិច្ចការបរទេសសហភាពអឺរ៉ុប។
    - និងលោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្ដីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់អន្តរជាតិ លោក **ម៉ាក ថៃយល័រ** ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។
    - ចូលរួមជំនួបពិភាក្សាការងារ រវាង SOMTC កម្ពុជាជាមួយប្រតិភូ ASEAN-ACT តាមប្រព័ន្ធវីដេអូសន្និសីទ នៅទីស្ដីការក្រសួងមហាផ្ទៃ។
  - លោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុម បានចូលរួមប្រជុំចែករំលែកព័ត៌មានបច្ចុប្បន្នភាពរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីតកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ភ្នំពេញ។
  - លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុម បានចូលរួមសម្របសម្រួល និងធ្វើជាគ្រូឧទ្ទេសវគ្គបណ្ដុះបណ្ដាលស្ដីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប នៅខេត្តកោះកុង។
  - និងចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅខេត្តសៀមរាប

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង និងជាសមាជិកអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ) បានចូលរួមកិច្ចប្រជុំលើកទី២ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅសណ្ឋាគាររ៉េស៊ីដង់សុខា ភ្នំពេញ។<br>- និងបានចូលរួមកិច្ចប្រជុំរបស់ក្រុមការងារទី៣ ទទួលបន្ទុកអនុវត្តសកម្មភាពនៅក្នុងលទ្ធផលជាក់ស្តែងទី៧ និងទី៨ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានអ.អ.ផ និងជាសហប្រធានក្រុមការងារទី៣ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធានអ.អ.ផ និងជាសហប្រធានក្រុមការងារទី៣ កិច្ចប្រជុំនេះធ្វើឡើងតាមប្រព័ន្ធវីដេអូហ្សូម។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គ្រោង ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ជាមួយអង្គការយែរប្រចាំកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- ចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកោះកុង។<br>- ចូលរួមកិច្ចប្រជុំក្រុមការងាររបាយការណ៍ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់កម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់គ.ជ.ប.ជ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៧ ខែមេសា ក្រោមការដឹកនាំសម្របសម្រួលដោយឯកឧត្តម **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរងគ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៨លើក អ្នកចូលរួមសរុបចំនួន ៦៨៩នាក់ (ស្រី ៣៣៥នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមីនា ត្រីមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅអនុវត្តបន្ត អ្នកចូលរួម ៥៩នាក់ ស្រី២៨នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៨លើក អ្នកចូលរួម ៣៦៤នាក់ ស្រី១៨២នាក់។ |
| **ខេត្តក្រចេះ** | - លេខាធិការដ្ឋាន គជ.ប.ខ. បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តឆ្នាំ២០២២ តាមប្រព័ន្ធ Zoom ០១លើក អ្នកចូលរួម ៣០នាក់ ស្រី២១នាក់។<br>- ស្នងការដ្ឋាននគរបាលខេត្តបានចាត់មន្ត្រីនគរបាលចំនួន០៦រូប ស្រី០១រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ដែលរៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ ០១លើក។ |

| | |
|---|---|
| ខេត្តព្រៃវែង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០២២ ០១លើក អ្នកចូលរួម ៣០នាក់ ស្រី១៨នាក់។<br>- មន្ត្រីជំនាញនៃមន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាល ០២លើក៖ ១.ស្តីពីការទប់ស្កាត់ការរំលោភបំពានលើស្ត្រី និងកុមារ រៀបចំដោយក្រសួងកិច្ចការនារី នៅខេត្តស្ទឹងត្រែង។ ២.ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តតាកែវ។<br>- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធឱ្យធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតអំពីការជួញដូរមនុស្ស តាមប្រព័ន្ធ Zoom។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារស្តីពីការត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ២០២២ បានចំនួន០១លើក ដែលមានអ្នកចូលរួមសរុប ២០នាក់ ស្រី០៩នាក់ នៅបន្ទប់ប្រជុំលេខ១ សាលាខេត្ត។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ ០៤លើក អ្នកចូលរួមចំនួន ១១៥នាក់ ស្រី៤០នាក់។<br>- លោកស្រីប្រធាន អនុប្រធាន លេខាធិការដ្ឋាន បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការយល់ដឹងពីមូលដ្ឋាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខនៅសហគមន៍ ០១លើក។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការសម្របសម្រួលជូន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IOM លើការចាត់អញ្ជើញសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក។ |
| ខេត្តស្វាយរៀង | - លោកជំទាវ ឯក សុវណ្ណការៈ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស ឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ ។ |
| ខេត្តព្រះវិហារ | - លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០២២ ០១លើក អ្នកចូលរួម ៣១នាក់ ស្រី១០នាក់។ |
| ខេត្តបន្ទាយមានជ័យ | លោកស្រី **ឈា ម៉ានិត** ប្រធានមណ្ឌលសំចតប៉ោយប៉ែត៖<br>- បានចូលរួមសិក្ខាសាលា ស្តីពីការធ្វើបច្ចុប្បន្នភាពលើ សារាចរណ៍ណែនាំការងារសមាហរណកម្មតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលស្នាក់នៅក្នុងមណ្ឌល និងសហគមន៍ និងទម្រង់គ្រប់គ្រងករណី ០១លើក។<br>- ចូលរួមប្រជុំពិភាក្សាបន្ត និងធ្វើបច្ចុប្បន្នភាព សៀវភៅគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ០១លើក។ |
| ខេត្តប៉ៃលិន | - លោកស្រី **ឡេញ ឈាង** អភិបាលរងខេត្ត បានចូលរួមប្រជុំផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍របស់គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ(ACWC)ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន តាមប្រព័ន្ធZOOM។<br>- និងបានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការវិភាគលើការអនុវត្តគោលនយោបាយឆ្លើយតបនឹងអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW)។ |

| | |
|---|---|
| ខេត្តកំពង់ចាម | - លោកស្រី **ង៉ោក ចរិយា** អនុប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី"ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស" ដែលរៀបចំដោយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រីនឹងកុមារ នៅសណ្ឋាគារភ្នំប្រុស ០១លើក។<br>- ក្រុមការងារទេសន្តរប្រវេសន៍របស់មន្ទីរការងារបានចូលរួមប្រជុំតាមZoom ជាមួយអង្គការ ILO ១លើក ដើម្បីពិភាក្សាការងារអាទិភាពសម្រាប់ឆ្នាំ២០២២ ។<br>- លោកស្រី **ខៀវ សុជាតិ** សមាជិកក្រុមការងារទេសន្តរប្រវេសន៍ ប្រជុំជាមួយក្រុមការងារ និងលេខាធិការដ្ឋាន គ.ខ.ប.ជ នៅសាលាខេត្ត០២លើក ព្រមទាំងបានធ្វើបទបង្ហាញអំពី នីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេសចំនួន ០១លើក នៅស្រុកស្ទឹងត្រង់ អ្នកចូលរួម២២នាក់ស្រី០៩នាក់។ |
| ខេត្តកំពត | - លេខាធិការដ្ឋានបានរៀបចំកិច្ចប្រជុំការងារប្រចាំខែ បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងការបំពេញកម្រងសំណួរសម្រាប់វាយតម្លៃការងារឆ្នាំ២០២២ មានអ្នកចូលរួម ២០នាក់ ស្រី១០នាក់ ។ |
| បាត់ដំបង | - បានចូលរួមប្រជុំត្រីមាសទី១ របស់គម្រោងស្តីពី សុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា រយៈ០៣ឆ្នាំ(២០២២-២០២៤) គាំទ្រដោយអង្គការការីតាស់ស្វីស។<br>- បានចូលរួមជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិទទួលបានការងារ ០១លើក អ្នកចូលរួម ១៦នាក់ ស្រី១៣នាក់។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការធ្វើបច្ចុប្បន្នភាពលើកសារចរណ៍ណែនាំការងារសមាហរណកម្មតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលនិងសហគមន៍ និងទម្រង់គ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ |
| ខេត្តកំពង់ឆ្នាំង | - លោកជំទាវប្រធានលេខាធិការដ្ឋានគជ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍ ស្តីពី.ប.ខ.លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមីនា ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្សអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ តាមប្រព័ន្ធ Zoom ០១លើក អ្នកចូលរួម ០៦នាក់ ស្រី០៤នាក់។ |